សុន្ទរកថារបស់**ឯកឧត្តម លោក ម៉ាសាហ៊្វូមី គូរ៉ូគី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន

០៨ កុម្ភៈ ២០១២

**សូមគោរព លោក អ៊ឹង ប៉ុឡា នាយកប្រតិបត្តិអង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមា នសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយ អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍(COCD)។

ជំនួយដែលមានថវិកាសរុបចំនួន ៦៥,៧៥០ដុល្លាអាមេរិកត្រូវបានផ្តល់ជូនសម្រាប់គម្រោងសាងសង់អគារសិក្សាថ្មីមួយខ្នងមាន៥បន្ទប់ រួមទាំងតុ កៅអី និងបន្ទប់អនាម័យ ព្រមទាំងអាងទឹកមួយក្នុងសាលាបឋមសិក្សាក្បែរត្របូរីក្នុងខេត្តពោធិ៍សាត់។

តាមរយៈការស្នើសុំរបស់អង្គការ COCDនិងការចុះពិនិត្យទីតាំងគម្រោងដែលធ្វើឡើងដោយបុគ្គលិកស្ថានទូត យើងបានស្វែងយល់អំពីតម្រូវការចាំបាច់ក្នុងការសាងសង់អគារសិក្សាថ្មីដើម្បីជំនួសឲ្យអគារចាស់ និងសម្រួលដល់សិស្សានុសិស្សដែលមានចំនួនកើនឡើងក្នុងសាលាបឋមសិក្សាក្បែរត្របូរី។

វិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាលជប៉ុនជាមួយព្រះរាជាណាចក្រកម្ពុជា គឺដើម្បីលើកស្ទួយវិស័យអប់រំ។ ប្រទេសជប៉ុនបាននិងកំពុងបន្តគាំទ្រការសាងសង់អគារសិក្សាក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សាដើម្បីសម្រេចឲ្យបាននូវគោលការណ៍នៃការអប់រំសម្រាប់ទាំងអស់គ្នា និងការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីលើកកម្ពស់គុណភាពអប់រំ។

ខ្ញុំសង្ឃឹមថា ការសាងសង់អគារសិក្សា បន្ទប់អនាម័យ និងបរិក្ខារដទៃទៀតនឹងជួយធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌសិក្សាសម្រាប់កុមារ ហើយនិងជួយបង្កើនសមត្ថភាពសាលាបឋមសិក្សាក្បែរត្របូរីក្នុងការទទួលសិស្សមកពីចំណុចសន្ទ្រៃ ចំណុចមុល និងចំណុចរាំងហ្វារ ក្នុងភូមិក្បែរត្របូរី។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូនដោយអង្គការCOCD ហើយនិងត្រូវបានថែរក្សាយ៉ាងត្រឹមត្រូវដោយលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៅក្នុងសាលា។ ខ្ញុំក៏សង្ឃឹមផងដែរថាជំនួយសម្រាប់គម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!